OAKLAND UNIFIED SCHOOL DISTRICT

*Community Schools, Thriving Students*

# ស្តង់ដារនានាសំរាប់ការចូលរួមដ៏មានន័យពីក្រុមគ្រួសារ

## ស្តង់ដារទី 1: កម្មវិធីសិក្សាសំរាប់ មាតាបិតា / អ្នកថែរក្សា

គ្រួសារទាំងឡាយនឹងត្រូវបានគាំទ្រអមដោយជំនាញចញ្ចឹមបីបាច់ថែរក្សា និងអប់រំកូនចៅ ដោយមានការយល់អំពីការធំធាត់នៃកូនតូចៗ និងកូនពេញវ័យជំទង់ៗ និងការដាក់លក្ខខ័ណ្ឌនៅឯផ្ទះ ដែលជួយកូនៗជាសិស្សក្នុងវ័យ និងកំរិតថ្នាក់នីមួយៗ។ ជួយសាលារៀននានាអោយចេះយល់ដល់ក្រុមគ្រួសារទាំងឡាយ។

## ស្តង់ដារទី 2: ការប្រាស្រ័យទាក់ទងជាមួយ មាតាបិតា / អ្នកថែរក្សា

ក្រុមគ្រួសារទាំងឡាយ និងបុគ្គលិកសាលារៀន ចូលរួមក្នុងការប្រាស្រ័យទាក់ទងគ្នាដ៏មានន័យទៅវិញទៅមកជាធម្មតាអំពីការរៀនសូត្ររបស់កូនសិស្ស។

## ស្តង់ដារទី 3: កម្មវិធីចូលបំរើការដោយស្ម័គ្រចិត្តពីមាតាបិតា

ក្រុមគ្រួសារទាំងឡាយ ចូលរួមយ៉ាងសកម្មក្នុងនាមជាអ្នកស្ម័គ្រចិត្ត និងជាអ្នកស្តាប់ការនៅតាមទីសាលារៀន ឬតាមទីកន្លែងផ្សេងដើម្បីជួយកូនសិស្ស និងកម្មវិធីនានានៃសាលារៀន។

## ស្តង់ដារទី 4: ការរៀនសូតនៅឯផ្ទះ

ក្រុមគ្រួសារទាំងឡាយចូលរួមជាមួយនឹងកូនៗរបស់គេក្នុងសកម្មភាពរៀនសូត្រនៅឯផ្ទះ រួមមានដូចជាគេហកិច្ចការ និងកិច្ចសំរេចចិត្ត និងសកម្មវិធីផ្សេងៗទៀតទាក់ទងទៅនឹងកម្មវិធីសិក្សា។

## ស្តង់ដារទី 5: អំណាច និងការធ្វើកិច្ចសំរេចចិត្តរួមគ្នា

ក្រុមគ្រួសារទាំងឡាយ និងបុគ្គលិកសាលារៀន គឺជាដៃគូស្មើភាពគ្នាក្នុងការធ្វើកិច្ចសំរេចចិត្ត ដែលមានឥទ្ធិពលលើកុមារ និងគ្រួសារព្រមទាំងរួមគ្នាផ្តល់ដំណឹង ជះឥទ្ធិពល និងបង្កើតច្បាប់ប្រតិបត្តិ ការអនុវត្តន៍ជាទម្លាប់ និងកម្មវិធីនានា។

## ស្តង់ដារទី 6: ធនធាន និងកិច្ចសហការរួមគ្នាពីប្រជាសហគមន៍

សម្របសម្រួលធនធាន និងការបំរើសេវានានាសំរាប់ក្រុមគ្រួសារ កូនសិស្ស និងសាលារៀន ជាមួយនឹងស្ថាប័នជំនួញ ទីប្រឹក្សា និងក្រុមផ្សេងៗទៀត ព្រមទាំងបំរើសេវានានាដល់ប្រជាសហគមន៍។

## ចក្ខុវិស័យ

តាមរយៈការចូលរួមដ៏មានន័យពីក្រុមគ្រួសារ យើងស្រមើលស្រមៃឃើញនូវប្រព័ន្ធសិក្សាដែលបានផ្លាស់ប្តូរ ដែលត្រូវបានគេប្រឈមមុខដោយផ្ទាល់ ហើយដែលបានលើកមកដោះស្រាយបញ្ហាមិនស្មើភាពគ្នា និងភាពអយុត្តិធម៌ ដើម្បីអោយកូនសិស្សគ្រប់ៗរូបក្នុងសង្កាត់សាលារៀនអូកឡិនដ៍ បានរៀន និងបានក្លាយទៅជាសមាជិកសហគមន៍នៃយើងដែលចេះចូលរួមពេញលេញ។

## គោលបំណង

គោលបំណងនៃការចូលរួមដ៏មានន័យពីក្រុមគ្រួសារ ដើម្បីជំរុញទឹកចិត្ត ទាក់ទាញអោយមកចូលរួម និងគាំទ្រកូនសិស្ស ក្រុមគ្រួសារ និងសហគមន៍នៃសង្កាត់សាលារៀនអូកឡិនដ៍ អោយក្លាយទៅជាម្ចាស់រួមគ្នាពិតប្រាកដនៃសាលារៀនានារបស់យើង ដែលមានទំនួលខុសត្រូវរួមគ្នាលើការជួយអោយកូនសិស្សគ្រប់ៗរូបចេះត្រៀមខ្លួនជាស្រេចដើម្បីមហាវិទ្យាល័យ និងអាជីព។ តាមរយៈការរៀបចំសហគមន៍ និងតាមការបង្កើតសមត្ថិភាពនៃសង្កាត់សាលារៀនអូកឡិនដ៍នេះ យើងនឹងពង្រីកអោយមានការចូលរួមរៀនសូត្រ ដឹកនាំ និងធ្វើការតស៊ូរមតិ ដែលទទួលបាននូវលទ្ធផលសំរេចបានជោគជ័យកំរិតខ្ពស់ក្នុងការសិក្សា និងមានឱកាសនានាក្នុងជីវិតសំរាប់កូនសិស្សម្នាក់ៗ និងសំរាប់សហគមន៍សាលារៀនទាំងមូល។

## គុណតម្លៃ

• យើងអោយតម្លៃលើបទពិសោធន៍ខុសៗគ្នា និងមានលក្ខណៈពិសេសៗ នៃក្រុមគ្រួសារទាំងឡាយនៅក្នុងសហគមន៍នៃយើង។

• យើងអោយតម្លៃលើការចូលរួមជាមួយកូនសិស្ស និងក្រុមគ្រួសារទាំងឡាយ ដោយសេចក្តីស្រឡាញ់ ដោយការយកចិត្តទុកដាក់ និងសេចក្តីមេត្តា និងការគោរព។

• យើងអោយតម្លៃលើកូនសិស្សទាំងឡាយថាជាមេដឹកនាំ និងជាភ្នាក់ងារផ្លាស់ប្តូរ។

• យើងអោយតម្លៃលើការធ្វើកិច្ចសំរេចចិត្តបែបប្រជាធិបតេយ្យពិតប្រាកដ ជាទីដែលកូនសិស្ស ក្រុមគ្រួសារ និងប្រជាសហគមន៍ គឺជាដៃគូស្មើភាពគ្នា។

• យើងអោយតម្លៃលើសិទ្ធិសម្រេចផ្ទាល់ខ្លួនជាមួយនឹងប្រជាសហគមន៍ និងការផ្តល់លទ្ធភាពនៃក្រុមគ្រួសារ។

• យើងអោយតម្លៃលើការលុបបំបាត់ចោលនូវភាពខុសគ្នារវាងបុគ្គលិកនៃសង្កាត់សាលារៀនអូកឡិនដ៍ និងកូនសិស្ស ក្រុមគ្រួសារ និងប្រជាសហគមន៍ ដើម្បីចូលរួមក្នុងការតស៊ូធ្វើការផ្លាស់ប្តូរវិជ្ជមានប្រកបដោយជោគជ័យ។

## សំរាប់ពត៌មានបន្ថែម សូមទំនាក់ទំនង :

Raquel Jiménez
អ្នកឯកទេសខាងការចូលរួមពីក្រុមគ្រួសារ និងសហគមន៍ប្រចាំសង្កាត់សាលារៀនអូកឡិនដ៍
raquel.jimenez@ousd.k12.ca.us
(510) 434-7766, ext. 233

បានកែតម្រូវ : 4 មេសា 2012